E306/3/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 04 / 06 / 2014
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៤

ជូនចំពោះ: លោក Michael G. KARNAVAS
លោក អាង ឧត្តម

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រម, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់ក្នុងសំណុំរឿង ០០២

កម្មវត្ថុ: សេចក្តីសម្រេចលើសំណើសុំការអនុញ្ញាតដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*

1. អង្គជំនុំជម្រះបានទទួលសំណើរបស់លោក Michael G. KARNAVAS និងលោក អាង ឧត្តម ដែលជាមេធាវីតំណាងឱ្យជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និងជាអតីតមេធាវីការពារក្តីឱ្យ អៀង សារី (អ្នកដាក់ពាក្យសុំ) សុំដាក់*សារណាក្នុងនាមជាអ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ពាក់ព័ន្ធនឹងការអនុវត្តអាជ្ញាយុកាលបទល្មើសនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ("សំណើសុំ") (ឯកសារ E306/3)។

2. កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានអញ្ជើញភាគីនានាក្នុងសំណុំរឿង ០០២ លើកឡើងនូវការយល់ឃើញរបស់ខ្លួនទាក់ទិននឹងបញ្ហាចំនួនពីរដែលមេធាវីការពារក្តី អៀង សារី បានលើកឡើងនៅឆ្នាំ ២០១១ មុនពេល អៀង សារី ទទួលមរណៈភាព ពោលគឺការអនុវត្តអាជ្ញា-យុកាលបទល្មើសនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងយុត្តាធិការរបស់តុលាការនេះទៅលើការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ឯកសារ E306)។ ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានដាក់ចម្លើយតបនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៤ (ឯកសារ E306/1, E306/2)។

3. អ្នកដាក់ពាក្យសុំលើកឡើងថា៖

> ពួកគេស្ថិតក្នុងស្ថានភាពមួយយ៉ាងល្អដែលមានលទ្ធភាពជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងឋានៈជា *អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ដែលបានស្រាវជ្រាវ និងរៀបចំសារណាអំពីបញ្ហានេះនៅក្នុងសំណុំរឿង០០៣ និងបានដាក់អញ្ញត្រកម្មបឋមនៅក្នុងសំណុំរឿង០០២ ព្រមទាំងបានលើកឡើងនូវទឡ្ហីករណ៍ផ្ទាល់មាត់អំពីបញ្ហានេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងពេលសវនាការបឋម។ *ការដាក់សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* មិនប៉ះពាល់ដល់ភាគីណាមួយនោះទេ។ សារណាមិនបានលើកឡើងអំពីអង្គហេតុ ឬការចោទប្រកាន់ ប៉ុន្តែសារណានេះបានលើកឡើងតែបញ្ហាផ្លូវច្បាប់ដាច់ដោយឡែក ថាតើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវតម្រូវឱ្យមានអាជ្ញាយុកាលដែរ ឬយ៉ាងណា។

4. វិធាន ៣៣ នៃវិធានផ្ទៃក្នុងចែងថា៖ "បើយល់ថាចាំបាច់ដើម្បីវិនិច្ឆ័យទោសឱ្យបានត្រឹមត្រូវ [...] អង្គជំនុំជម្រះអាចអញ្ជើញ ឬផ្តល់ឱកាសឱ្យអង្គការ ឬបុគ្គលណាមួយប្រគល់ជូននូវសារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងបញ្ហាណាមួយក៏បានក្នុងនាមជាអ្នកឯកទេសអមតុលាការ"។ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល បានបដិសេធចោលជាច្រើនលើកច្រើនសាលើសំណើសុំដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ដោយសារអង្គជំនុំជម្រះទាំងនោះយល់ឃើញថាខ្លួនបានទទួលព័ត៌មានគ្រប់គ្រាន់រួចហើយលើបញ្ហានេះ ឬក៏ការដាក់*សារណារបស់អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ធ្វើឱ្យមានការពន្យារពេលដោយមិនចាំបាច់ (ឯកសារ D99/3/17, D158/5/1/14, F16/3)។ បន្ថែមពីលើនេះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា *សារណារបស់អ្នកដែល*

*មិនមែនជាភាគីក្នុងរឿងក្តី* មិនត្រូវ "ធ្វើឡើងដោយបុគ្គលដែលបំរើការងារនៅតុលាការ ឬក៏ការិយាល័យណាមួយរបស់តុលាការឡើយ" (ឯកសារ F7/2 សំណុំរឿង ០០១)។

5. អង្គជំនុំជម្រះប្រើប្រាស់សំអាងហេតុនេះ និងកត់សម្គាល់ឃើញថា *អ្នកដែលមិនមែនជាភាគីក្នុងរឿងក្តី* ជាធម្មតា គឺជាអ្នកប្រឹក្សាឯករាជ្យ និងឥតលម្អៀងចំពោះតុលាការ ដែលមានតួនាទីគ្រាន់តែផ្តល់យោបល់ ប៉ុន្តែមិនត្រូវប្រកាន់ជំហរណាមួយនោះទេ (ឯកសារ D99/3/18.31)។ នៅក្នុងសារណាពីមុនៗ អ្នកដាក់ពាក្យសុំបានគាំទ្រដល់ការអនុវត្តបទដ្ឋាននេះ (ឯកសារ D99/3/18 កថាខណ្ឌ ១១)។ អង្គជំនុំជម្រះយល់ឃើញថា បុគ្គលដែលបានធ្វើសកម្មភាពឱ្យភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន និងបានតាំងខ្លួនជាមេធាវីរបស់ភាគីមួយនៅក្នុងសំណុំរឿង ០០៣ ដែលជាអ្នកដាក់ពាក្យស្នើសុំនៅក្នុងសំណើសុំនេះ គឺមិនអាចប្រកាន់ជំហរជាសត្យានុម័តមួយ ឬមិនគិតពីផលប្រយោជន៍នៃលទ្ធផលរបស់ដំណើរការនីតិវិធីនោះទេ។ ដោយសារតែអ្នកដាក់ពាក្យសុំជាប់ពាក់ព័ន្ធជាមួយនឹងតុលាការ ឬការិយាល័យរបស់តុលាការ និងមិនអាចចាត់ទុកជាអ្នកប្រឹក្សាឯករាជ្យ និងឥតលម្អៀងចំពោះអង្គជំនុំជម្រះបានទេ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធចោលសំណើសុំនេះ។